# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## អគ្គនាយកដ្ឋានកសិកម្ម
### នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ

**បែបបទនៃការផ្ដល់វិញ្ញាបនបត្រភូតគាមអនាម័យ**
**សម្រាប់ការនាំចេញ ការនាំចេញទៅវិញ ការនាំចូល និងការដឹកជញ្ជូនឆ្លងកាត់**
**សម្រាប់ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ**



កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ:
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

ឆ្នាំ ២០១៩

## ១. សេចក្តីផ្តើម

ការត្រួតពិនិត្យភូតគាមអនាម័យមានគោលបំណងដើម្បីទប់ស្កាត់ការរីករាលដាលឆ្លងនូវសមាសភាពចង្រៃភូតគាមអនាម័យ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ពីតំបន់មួយទៅតំបន់មួយទៀត ក្នុងព្រះរាជាណាចក្រកម្ពុជា ចូល-ចេញ ឬឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជាតាមគ្រប់មធ្យោបាយដើម្បីការពារផលិតកម្មកសិកម្ម និងជីវសាស្ត្រចម្រុះ។

ម្ចាស់ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលនាំយក ឬ ដឹកជញ្ជូនចូល-ចេញ ឬ ឆ្លងកាត់ ព្រះរាជាណាចក្រកម្ពុជា ត្រូវសុំការត្រួតពិនិត្យ និងត្រូវគោរពតាមគ្រប់វិធានការភូតគាមអនាម័យ។

នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចទទួលខុសត្រូវលើការអនុវត្តដោយផ្ទាល់នូវការងារត្រួតពិនិត្យភូតគាមអនាម័យ។

- ការផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់ការនាំចេញ ត្រូវបានអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងបទបញ្ញត្តិ កិច្ចសន្យាពាណិជ្ជកម្ម កិច្ចព្រមព្រៀង អនុសញ្ញា និងបណ្តាឯកសារដទៃទៀតស្តីពីលក្ខខណ្ឌភូតគាមអនាម័យនៃប្រទេសនាំចូល
- ការផ្តល់វិញ្ញាបនបត្រនាំចូលសម្រាប់ទំនិញជាកម្មវត្ថុត្រួតពិនិត្យភូតគាមអនាម័យអនុវត្តតាមវិធានការភូតគាមអនាម័យនៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិនៃតំបន់ និងអន្តរជាតិ ដើម្បីគាំពារផលិតកម្មកសិកម្ម ជីវៈចម្រុះ និងកិច្ចសម្រួលពាណិជ្ជកម្មអន្តរជាតិ
- ការត្រួតពិនិត្យភូតគាមអនាម័យលើការដឹកជញ្ជូនទំនិញឆ្លងកាត់ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវគោរពតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ១៥ អនក្រ. បក. ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ និងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៧ស្តីពីប្រព័ន្ធឆ្លងកាត់គយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីកិច្ចសម្រួលការដឹកជញ្ជូនឆ្លងកាត់ទំនិញ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៦ និងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៨ស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យ ដើម្បីអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន អំពីការសម្របសម្រួលទំនិញឆ្លងកាត់ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣។

## ២. ទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ

ទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យរួមមាន៖

- រុក្ខជាតិ បំណែករុក្ខជាតិ ផលិតផលរុក្ខជាតិ និងផលិតផលកែច្នៃពីផលិតផលរុក្ខជាតិដែលអាចជាជម្រក និងចម្លងសមាសភាពចង្រៃ
- សម្ភារៈវេចខ្ចប់ ឡាំងឈើ កំណាត់ឈើ ឬមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ និងឃ្លាំងសន្និធិ
- ដី ឬដីដែលជាប់នឹងឫស ឬបំណែករុក្ខជាតិ
- សមាសភាពចង្រៃ ឬ សរីរៈមានប្រយោជន៍រស់ ឬងាប់
- ផលិតផលដែលគ្មានដើមកំណើតពីរុក្ខជាតិ តែអាចជាជម្រកនៃសមាសភាពចង្រៃ។



## ៣. នីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ

### ៣.១. បែបបទនៃការត្រួតពិនិត្យភូតគាមអនាម័យសម្រាប់ការនាំចេញ និងនាំចេញទៅវិញ

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងនាំចេញនូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យត្រូវជួបពិភាក្សាជាមួយសមត្ថកិច្ចភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម។ បែបបទនៃការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចេញអាស្រ័យទៅនឹងប្រភេទទំនិញ ទីកន្លែង ប្រភពទំនិញ និងដែនដី ឬប្រទេសជាទិសដៅនៃការនាំចូល (លក្ខខណ្ឌតម្រូវភូតគាមអនាម័យរបស់ប្រទេសនីមួយៗអាចខុសគ្នាអាស្រ័យទៅនឹងទីកន្លែងប្រភព និងប្រភេទផលិតផល)។

ជាទូទៅបែបបទនៃការនាំចេញ (ត្រូវបំពេញមុនការនាំចេញ) អាចបែងចែកជា៖

- ប្រភេទទំនិញមិនជាប់កម្រិតកំណត់៖ ការនាំចេញទំនិញប្រភេទរុក្ខជាតិ និងផលិតផលរុក្ខជាតិពីកម្ពុជាទៅកាន់ប្រទេស ឬដែនដីដែលធ្លាប់បាននាំចេញរួចហើយ (រដ្ឋាភិបាលទាំងនោះមិនបានដាក់លក្ខខណ្ឌពិសេស ឬតម្រូវឱ្យសមត្ថកិច្ចនៃរដ្ឋាភិបាលប្រទេសនាំចេញស្នើសុំតែផ្អែកលើលក្ខខណ្ឌផ្លូវច្បាប់ដែលមានជាធរមានរួចហើយ ដែលលក្ខខណ្ឌរាល់ការនាំចូលទាំងនោះត្រូវតែគោរព និងចាត់ចែងឱ្យមានអនុលោមភាព)
- ប្រភេទទំនិញជាប់កម្រិតកំណត់៖ ការនាំចេញទៅកាន់ទិសដៅប្រភេទនេះទាមទារឱ្យសមត្ថកិច្ចភូតគាមអនាម័យកម្ពុជាធ្វើសំណើសុំចរចារជាមួយសមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសនាំចូលតាមរយៈការស្នើសុំវាយតម្លៃហានិភ័យសមាសភាពចង្រៃពាក់ព័ន្ធនឹងការនាំចូលទំនិញដែលបានស្នើសុំ។ ការចរចារអាចចំណាយពេលពី១ ដល់ ៥ឆ្នាំដែលការនាំចេញពីកម្ពុជាអាចចាប់ផ្តើមបន្ទាប់ពីមានកិច្ចព្រមព្រៀង ពិធីសារ ឬឯកសារសមមូល បញ្ជាក់ពីការឯកភាពរវាងសមត្ថកិច្ច ភូតគាមអនាម័យនៃប្រទេសទាំងពីរ។ ការឯកភាពនេះ អាចមានរហូតដល់កម្រិតតំបន់ដូចជាកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន (ASEAN Trade in Goods Agreement) ជាដើម។

ការបំពេញសំណុំលិខិតសុំការត្រួតពិនិត្យភូតគាមអនាម័យអាចប្រព្រឹត្តទៅជាដំណាក់កាលដូចតទៅ៖

### ក. ដំណាក់កាលទី១៖ ការដាក់ពាក្យស្នើសុំ

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងនាំចេញនូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យទៅកាន់ប្រទេស ឬដែនដីនៃប្រភេទទំនិញមិនជាប់កម្រិតកំណត់ត្រូវដាក់ពាក្យបំពេញបែបបទស្នើសុំ (១០ថ្ងៃមុនមានការកំណត់នាំចេញ) ការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញបញ្ញើបម្រុងនាំចេញនៅអគ្គនាយកដ្ឋានកសិកម្ម (នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ)។

សំណុំឯកសារស្នើសុំត្រូវភ្ជាប់មកជាមួយនូវ៖ (១) វិក្កយបត្រ (Invoice) (២) បញ្ជីវេចខ្ចប់ (Packing list) (៣) វិញ្ញាបនបត្រធូបនកម្ម (Fumigation Certificate) (ប្រសិនបើមាន និងត្រូវតែមានការតម្រូវពីប្រទេសនាំចូល) (៤) លិខិតអនុញ្ញាតនាំចូល (Import Permit) (ប្រសិនបើមាន) (៥) បណ្តាលក្ខខណ្ឌភូតគាមអនាម័យនៃប្រទេសនាំចូលក្នុងសណ្ឋានជាកិច្ចព្រមព្រៀង ពិធីសារ...(ប្រសិនបើមាន) (៦) វិញ្ញាបនបត្រភូតគាមអនាម័យ (Phytosanitary Certificate) ដែលចេញដោយសមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសជាប្រភពដើមនៃទំនិញ (ក្នុងករណីសុំនាំចេញទៅវិញ)។ *សំណុំឯកសារចាប់ពី (១) ដល់ (៥) សម្រាប់ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រភូតគាមអនាម័យ និងបន្ថែម (៦) សម្រាប់ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រភូតគាមអនាម័យការនាំចេញទៅវិញ។

### ខ. ដំណាក់កាលទី២៖ ការត្រួតពិនិត្យ និងយកសំណាក

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានដាក់ពាក្យស្នើសុំការត្រួតពិនិត្យត្រូវរង់ចាំការសម្របសម្រួល និងណាត់ពេល(ពេលដែលទំនិញបញ្ញើបានរៀបចំរួច) ដើម្បីសមត្ថកិច្ចភូតគាមអនាម័យចុះធ្វើការត្រួតពិនិត្យដល់ទីកន្លែងបម្រុងផ្ទុកដឹកចេញទៅកាន់កំពង់ផែ។ ក្នុងករណី



ដែលលទ្ធផលត្រួតពិនិត្យទំនិញបញ្ញើខាងលើ អាចឱ្យសមត្ថកិច្ចធ្វើការសន្និដ្ឋានបានថា ទំនិញបញ្ញើដែលបានត្រួតពិនិត្យពិតជាមាន ឬមិនមានអនុលោមភាពតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃប្រទេសនាំចូល នោះអាចឈានទៅដល់ដំណាក់កាលទី៥។

## គ. ដំណាក់កាលទី៣៖ ការវិភាគសំណាក

ក្នុងករណីដែលគ្មានការសង្ស័យ នោះសមត្ថកិច្ចអាចបញ្ចប់របាយការណ៍ត្រួតពិនិត្យ និងស្នើសុំការចេញផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យ។ ផ្ទុយទៅវិញ ប្រសិនបើមានសញ្ញាសង្ស័យក្នុងពេលត្រួតពិនិត្យ នោះសមត្ថកិច្ចភូតគាមអនាម័យត្រូវយកសំណាកបញ្ជូនទៅវិភាគនៅមន្ទីរពិសោធន៍រោគវិនិច្ឆ័យភូតគាមសមាសភាពចង្រៃ (ចំណាយពេលបន្ថែមពី១-៣ថ្ងៃ) ។ បើមានវត្តមានសមាសភាពចង្រៃក្នុងពេលត្រួតពិនិត្យ និងដែលបញ្ជាក់ថា ទំនិញមិនស្របតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃប្រទេសនាំចូល សមត្ថកិច្ចត្រូវតម្រូវឱ្យម្ចាស់ទំនិញចាត់វិធានការកែតម្រូវដូចជា ធ្វើការកម្ចាត់សមាសភាពចង្រៃដោយប្រើឧស្ម័នពុល ឬធូបនកម្ម (Fumigation) ដែលត្រូវចំណាយពេលបន្ថែមរហូតដល់៥ថ្ងៃ។

ក្នុងករណីដែលលទ្ធផលត្រួតពិនិត្យទំនិញបញ្ញើខាងលើអាចឱ្យសមត្ថកិច្ចធ្វើការសន្និដ្ឋានបានថា ទំនិញបញ្ញើដែលបានត្រួតពិនិត្យពិតជាមាន ឬមិនមានអនុលោមភាពតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃប្រទេសនាំចូល នោះអាចឈានទៅដល់ដំណាក់កាលទី៥។



## ឃ. ដំណាក់កាលទី៤៖ ការកែតម្រូវទំនិញឱ្យស្របតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃប្រទេសនាំចូល

ក្នុងករណីដែលមានវត្តមានសមាសភាពចង្រៃ ក្នុងពេលត្រួតពិនិត្យ និង/ ឬលទ្ធផលនៃការវិភាគនៅមន្ទីរពិសោធន៍ដែលបញ្ជាក់ថាទំនិញមិនស្របតាមលក្ខខណ្ឌ តម្រូវភូតគាមអនាម័យនៃប្រទេសនាំចូល សមត្ថកិច្ចភូតគាមអនាម័យត្រូវតម្រូវឱ្យម្ចាស់ទំនិញចាត់វិធានការកែតម្រូវ (ប្រសិនបើអាចកែតម្រូវបាន)ដូចជាធ្វើការកម្ចាត់សមាសភាពចង្រៃដោយប្រើឧស្ម័នពុល (Fumigation) ដែលត្រូវចំណាយពេលបន្ថែមរហូតដល់៥ថ្ងៃ។ ផ្ទុយទៅវិញក្នុងករណីមិនអាចកែប្រែបាន សមត្ថកិច្ចភូតគាមអនាម័យអាចបដិសេធការចេញផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យ(មិនអាចនាំចេញបាន)។ ក្នុងករណីដែលលទ្ធផលត្រួតពិនិត្យទំនិញបញ្ញើខាងលើ អាចឱ្យសមត្ថកិច្ចធ្វើការសន្និដ្ឋានបានថាទំនិញបញ្ញើដែលបានត្រួតពិនិត្យពិតជាមាន ឬមិនមានអនុលោមភាពតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃប្រទេសនាំចូល នោះអាចឈានទៅដល់ដំណាក់កាលទី៥។

## ង. ដំណាក់កាលទី៥៖ ការចេញផ្តល់ ឬ បដិសេធផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យ

យោងតាមការសន្និដ្ឋានក្នុងរបាយការណ៍ត្រួតពិនិត្យរបស់សមត្ថកិច្ចភូតគាមអនាម័យ (លទ្ធផលនៃការត្រួតពិនិត្យដោយភ្នែកផ្ទាល់ ដោយការវិភាគ ដោយការពិនិត្យឡើងវិញ បន្ទាប់ពីកែតម្រូវទំនិញ) នោះទំនិញបញ្ញើ ដែលស្នើសុំនឹងត្រូវទទួលបានការបដិសេធ ឬការផ្តល់ជូននូវវិញ្ញាបនបត្រភូតគាមអនាម័យ។



## ៣.២. បែបបទនៃការត្រួតពិនិត្យភូតគាមអនាម័យសម្រាប់ការនាំចូល

ទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យមានហានិភ័យសមាសភាពចង្រៃខ្ពស់រួមមាន៖

- ពូជ និងបំណែកពូជរុក្ខជាតិសម្រាប់ដាំដុះបន្ត ពូជដំណាំជាលិកាវប្បកម្ម (Tissue culture) ប្រភេទរុក្ខជាតិធ្វើតេស្ដដកចេញពីមេបាដើម ជាលិកាបណ្ដុះសារពាង្គកាយដែលបានកែសំរួលហ្សែន
- សត្វល្អិតរស់ អតិសុខុមប្រាណ ភ្នាក់ងារជីវសាស្ត្រ ផ្សិត
- អាល់ហ្គា ដី ឬដីកំប៉ុស្ដិ៍ ដែលកើតឡើងពីកំទេចកំទីរុក្ខជាតិពុកផុយប្រើសម្រាប់បណ្ដុះ ឬ ដាំ ឬ បង្កើនជីជាតិដី
- ផលិតផល បន្លែ ផ្លែឈើស្រស់ និងមើម ឬពន្លកក្លៀងស្រស់ និងពពួកស្លែ ដែលមានបំណងនាំចូលពីប្រទេសជាប្រភពដែលមិនធ្លាប់ចូលមកកម្ពុជា
- បណ្ដាទំនិញដទៃទៀតដែលចាត់ក្នុងកម្រិតហានិភ័យនៃស្តង់ដារភូតគាមអនាម័យអន្តរជាតិលេខ៣២ (ISPM32) ក្នុងក្រុមទី៣ និងទី៤ ស្ដីពីចំណាត់ថ្នាក់ទំនិញអាស្រ័យលើកម្រិតហានិភ័យបង្កឡើងដោយសមាសភាពចង្រៃ។



### ក. ដំណាក់កាលទី១៖ ការដាក់ពាក្យស្នើសុំ

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងនាំចូលនូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យដែលស្ថិតក្នុងបញ្ជីប្រភេទទំនិញមានសក្តានុពលហានិភ័យខ្ពស់នៃសមាសភាពចង្រៃ (ប្រកាសលេខ ៣៤៦ ប្រក.កសក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០ ស្ដីពីនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ) ត្រូវបំពេញសំណុំបែបបទស្នើសុំជាមុននៅអគ្គនាយកដ្ឋានកសិកម្មដើម្បីទទួលបានវិញ្ញាបនបត្រអនុញ្ញាតនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ (Import Certificate for Plant Qurantine Material) ដោយភ្ជាប់មកជាមួយនូវឯកសារ៖(១)បញ្ជីឈ្មោះសមាសភាពចង្រៃមានវត្តមានរាតត្បាតក្នុងផលិតកម្ម និងការរក្សាទុកទំនិញដែលស្នើសុំក្នុងប្រទេសជាប្រភពកំណើតផលិតផល និងក្នុងប្រទេសដែលត្រូវដឹកជញ្ជូនឆ្លងកាត់(ក្នុងករណីត្រូវឆ្លងកាត់ប្រទេសទី២មុនមកដល់កម្ពុជា) (២) ឯកសារបច្ចេកទេសប្រព្រឹត្តកម្ម (Phytosanitary Treatment) នានាលើទំនិញដែលស្នើសុំ។ ឯកសារ (១) និង (២) ត្រូវតែជាឯកសារដែលចេញដោយអង្គភាពជាតិការពាររុក្ខជាតិ (National Plant Protection Organization-NPPO) នៃប្រទេសប្រភពដើមនៃទំនិញ។ ទំនិញដែលបានស្នើសុំអាចចាប់ផ្ដើមធ្វើការនាំចូលមកកម្ពុជាបានក្នុងករណីដែលការស្នើសុំត្រូវបានផ្ដល់ជូននូវវិញ្ញាបនបត្រអនុញ្ញាតនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យពី អគ្គនាយកដ្ឋានកសិកម្មដោយមាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យអនុវត្តដោយផ្ទាល់នូវសមត្ថកិច្ចភូតគាមអនាម័យ និងត្រូវបានចាត់ចែងវិធានការស្របតាមលក្ខខណ្ឌតម្រូវដែលកំណត់ដោយវិញ្ញាបនបត្រអនុញ្ញាតនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ។

### ខ ដំណាក់កាលទី២៖ ការធ្វើវិភាគហានិភ័យ

អគ្គនាយកដ្ឋានកសិកម្ម នឹងឆ្លើយតបអំពីលទ្ធផលនៃការវិភាគហានិភ័យក្នុងរយៈពេល១៥ថ្ងៃ ក្រោយពីទទួលបានសំណុំឯកសារខាងលើ ដែលជាលទ្ធផល៖

- បដិសេធការនាំចូល ក្នុងករណីដែលលទ្ធផលនៃការវិភាគហានិភ័យសមាសភាពចង្រៃបឋមបង្ហាញពីកម្រិតហានិភ័យមិនអាចគ្រប់គ្រងបាន
- តម្រូវឱ្យមានការស្នើសុំនាំចូលជាផ្លូវការពីអង្គភាពជាតិការពាររុក្ខជាតិនៃប្រទេសប្រភពដើមទំនិញ ក្នុងករណីដែលលទ្ធផលនៃការវាយតម្លៃហានិភ័យសមាសភាពចង្រៃមិនអាចវាយតម្លៃបានច្បាស់លាស់។ ករណីនេះតម្រូវឱ្យអង្គភាពជាតិការពាររុក្ខជាតិខាងលើផ្ដល់នូវឯកសារពាក់ព័ន្ធនឹងផលិតកម្មទំនិញដែលស្នើសុំដើម្បីគាំទ្រដល់ការវាយតម្លៃហានិភ័យសមាសភាពចង្រៃការវាយតម្លៃអាចឈានដល់ការបញ្ជូន

សមត្ថកិច្ចភូតគាមអនាម័យកម្ពុជា ទៅពិនិត្យផ្ទាល់ដល់ទីកន្លែងផលិតកម្ម ក្រោមការចំណាយរបស់អ្នកស្នើសុំ

- ផ្តល់ការអនុញ្ញាតការនាំចូល (វិញ្ញាបនបត្រអនុញ្ញាតនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ) ក្នុងករណីដែលលទ្ធផលនៃការវិភាគហានិភ័យសមាសភាពចង្រៃខាងលើបង្ហាញពីកម្រិតហានិភ័យដែលអាចគ្រប់គ្រងបាន(អាចភ្ជាប់ដោយលក្ខខណ្ឌ)។



## គ. ដំណាក់កាលទី៣៖ ការត្រួតពិនិត្យ

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងនាំចូលនូវគ្រប់ប្រភេទទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យដែលស្ថិត ឬមិនស្ថិតក្នុងបញ្ជីប្រភេទទំនិញមានសក្តានុពលហានិភ័យខ្ពស់នៃសមាសភាពចង្រៃ (ប្រកាសលេខ៣៤៦ ប្រក.កសក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ) ត្រូវបំពេញសំណុំបែបបទស្នើសុំការត្រួតពិនិត្យភូតគាមអនាម័យនៅស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

(១) វិញ្ញាបនបត្រភូតគាមអនាម័យ (Phytosanitary Certificate) ដែលចេញដោយសមត្ថកិច្ចនៃអង្គភាពជាតិការពាររុក្ខជាតិនៃប្រទេសប្រភពដើមទំនិញ និង/ឬវិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់ការនាំចេញទៅវិញ (Phytosanitary Certificate for Re-export) ដែលចេញដោយប្រទេសនាំចេញ និង/ឬប្រទេសនាំចេញទៅវិញ (ជាគំរូច្បាប់ដើម) (២)វិក្កយបត្រ(Invoice) (៣)បញ្ជីវេចខ្ចប់ (Packing list) (៤)វិញ្ញាបនបត្រប្រព្រឹត្តិកម្មរម្ងាប់សមាសភាពចង្រៃ ដូចជាវិញ្ញាបនបត្រធូបនកម្ម (Fumigation Certificate) (ប្រសិនបើមាន) (៥) វិញ្ញាបនបត្រអនុញ្ញាតនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ (ចាំបាច់ត្រូវតែមានចំពោះទំនិញស្ថិតក្នុងបញ្ជីប្រភេទទំនិញមានសក្តានុពលហានិភ័យខ្ពស់នៃសមាសភាពចង្រៃ) (៦) លិខិតអនុញ្ញាតនាំចូលដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ក្នុងករណីដែលទំនិញជាសម្ភារៈកសិកម្ម មានពូជដំណាំ ជី ថ្នាំកសិកម្ម ចំណីសត្វ ជាដើម)។ ទំនិញបញ្ញើខាងលើអាចអនុញ្ញាតឲ្យបន្តដឹកជញ្ជូនឆ្លងកាត់ព្រំដែនចូលមកក្នុងប្រទេសកម្ពុជា ក្នុងករណីដែលមានឯកសារភ្ជាប់គ្រប់គ្រាន់ និងលទ្ធផលនៃការត្រួតពិនិត្យបង្ហាញថាស្ថានភាពទំនិញមានបរិមាណ ប្រភេទ និងសន្តិសុខភូតគាមអនាម័យស្របតាមការបញ្ជាក់នៃឯកសារ។

## ឃ. ដំណាក់កាលទី៤៖ ការដឹកជញ្ជូន ចាត់ចែងប្រើប្រាស់ ទុកដាក់ ឬចែកចាយ ទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ

រាល់ទំនិញបញ្ញើដែលបានទទួលការអនុញ្ញាតឱ្យដឹកជញ្ជូនចូលមកក្នុងប្រទេសកម្ពុជា ត្រូវតែដឹកជញ្ជូន និងចាត់ចែងប្រើប្រាស់ ទុកដាក់ ឬ ចែកចាយ តាមលក្ខខណ្ឌដែលបានកំណត់ក្នុងវិញ្ញាបនបត្រអនុញ្ញាតនាំចូលទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ និង/ឬ ការកំណត់របស់សមត្ថកិច្ចភូតគាមអនាម័យ។ ក្នុងករណីដែលមានបំណងផ្លាស់ប្តូរបំណងប្រើប្រាស់ ទុកដាក់ ចែកចាយ ម្ចាស់ទំនិញត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកដ្ឋានកសិកម្ម។ ម្ចាស់ទំនិញត្រូវបន្តតាមដានសន្តិសុខភូតគាមអនាម័យ (ការកកើតឡើងនូវសមាសភាពចង្រៃ ឬផ្តល់ប្រឹក្សាក្នុងករណី ដែលមានការកើតឡើងនូវសមាសភាពចង្រៃដែលសង្ស័យថាជាមុខសញ្ញាហាមឃាត់ភូតគាមអនាម័យ)។





## ៣.៣. បែបបទនៃការត្រួតពិនិត្យភូតគាមអនាម័យ សម្រាប់ការដឹកជញ្ជូនឆ្លងកាត់

### ក. ដំណាក់កាលទី១៖ ការដឹកជញ្ជូនទំនិញឆ្លងកាត់

- ត្រូវដឹកជញ្ជូនចូល និងចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា តែតាមច្រកទ្វារដែលបានកំណត់ដោយសមត្ថកិច្ចភូតគាមអនាម័យ
- ត្រូវដឹកជញ្ជូនឆ្លងកាត់ដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយប្រើតែផ្លូវជាតិនៃខេត្តដែលបានកំណត់ដោយសមត្ថកិច្ចភូតគាមអនាម័យ
- ត្រូវតែរៀបចំការដឹកជញ្ជូនដោយច្រកទំនិញក្នុងកុងតេន័របិទជិត ដែលធានាដល់លទ្ធភាពស៊ីលបាន និងមិនបែកធ្លុះធ្លាយតាមផ្លូវ និងមិនផ្ដល់លទ្ធភាពដល់ការសាយភាយសមាសភាពចង្រៃ (ប្រសិនបើមាន) ចេញពីទំនិញ
- រាល់មធ្យោបាយដឹកជញ្ជូន និងសំបកខាងក្រៅនៃកុងតេន័រទំនិញ ពុំត្រូវមានចម្លងមកជាមួយនូវសមាសភាពចង្រៃភូតគាមអនាម័យ និងសមាសភាពចង្រៃជាប់បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។

### ខ. ដំណាក់កាលទី២៖ នីតិវិធីភូតគាមអនាម័យលើការដឹកជញ្ជូនទំនិញឆ្លងកាត់

- រាល់ទំនិញបញ្ញើ ត្រូវភ្ជាប់ជាមួយនូវ (១) វិញ្ញាបនបត្រភូតគាមអនាម័យ (Phytosanitary Certificate) (២) វិក្កយបត្រ (Invoice) (៣) បញ្ជីវេចខ្ចប់ (Packing List) និង (៤) វិញ្ញាបនបត្រធូបនកម្ម (Fumigation Certificate) (ប្រសិនបើមាន)
- រាល់ទំនិញបញ្ញើដែលដឹកជញ្ជូនឆ្លងកាត់ដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែជាផលិតផលនៃប្រភពកំណើត (Place of Origin) នៅប្រទេសដើមកំណើត
- រាល់ការដឹកជញ្ជូនឆ្លងកាត់មួយលើកៗ នៅពេលដែលទំនិញបញ្ញើមកដល់ច្រកទ្វារចូល និងចេញ ម្ចាស់ទំនិញ ឬតំណាងត្រូវស្នើសុំការត្រួតពិនិត្យភូតគាមអនាម័យពីសមត្ថកិច្ចភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម ដោយមាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យអនុវត្តផ្ទាល់ និងត្រូវគោរពតាមនីតិវិធីដែលជាលទ្ធផលនៃការត្រួតពិនិត្យភូតគាមអនាម័យ
- ក្នុងពេលដឹកជញ្ជូនឆ្លងកាត់ដែនដីនៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់ទំនិញ ឬតំណាង ត្រូវរក្សាស៊ីលសុវត្ថិភាពភូតគាមអនាម័យ (Cambodia Plant Quarantine Seal) ពីច្រកទ្វារចូលរហូតដល់បានត្រួតពិនិត្យឯកភាពពីសមត្ថកិច្ចភូតគាមអនាម័យនៅច្រកទ្វារចេញ។ ម្ចាស់ទំនិញ ឬតំណាងត្រូវធានាថាមិនមានការបើក ឬរំលែកចេញ ឬដាក់បញ្ចូលបន្ថែមទំនិញ ឬសម្ភារៈដទៃទៅក្នុងកុងតេន័រផ្ទុកទំនិញបិទជិត ដែលដឹកជញ្ជូនឆ្លងកាត់ដែនដីនៃព្រះរាជាណាចក្រកម្ពុជា
- ក្នុងករណីដែលមានគ្រោះថ្នាក់ដោយចៃដន្យក្នុងពេលដឹកជញ្ជូនឆ្លងកាត់ដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបង្កឱ្យមានការបែកបាក់ ធ្លុះធ្លាយ ឬបើកកុងតេន័រទំនិញនោះ ម្ចាស់ទំនិញត្រូវរាយការណ៍ជាបន្ទាន់ទៅមន្ត្រីត្រួតពិនិត្យភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម។

### គ. ដំណាក់កាលទី៣៖ ការធានាទទួលខុសត្រូវរបស់ម្ចាស់ទំនិញ ឬតំណាងម្ចាស់ទំនិញ

- នៅពេលទំនិញដឹកជញ្ជូនឆ្លងកាត់មកដល់ច្រកទ្វារចូល និងចេញ ម្ចាស់ទំនិញត្រូវអញ្ជើញ និងសម្របសម្រួលជាមួយមន្ត្រីត្រួតពិនិត្យភូតគាមអនាម័យ ដើម្បីធ្វើការត្រួតពិនិត្យរួមគ្នាជាមួយស្ថាប័នដែលប្រចាំការនៅច្រកទ្វារចូល និងចេញ
- ក្នុងករណីទទួលបានការព្រមាន ឬសេចក្ដីជូនដំណឹងពីការបដិសេធមិនឱ្យចូលទំនិញពីសមត្ថកិច្ចភូតគាមអនាម័យនៃប្រទេសនាំចូល និង/ឬបំពានចំណុចណាមួយនៃចំណុច (ក) និង (ខ) ខាងលើនោះ អគ្គនាយកដ្ឋានកសិកម្មនឹងបញ្ឈប់ការអនុញ្ញាតដឹកជញ្ជូនឆ្លងកាត់ដោយគ្មានលក្ខខណ្ឌ។



**សមត្ថកិច្ចភូតគាមអនាម័យ**

**អាសយដ្ឋាន៖** អគារលេខ៥៤បេ-៤៩អេហ្វ ផ្លូវលេខ៣៩៥-៦៥៦

សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ៖** ០២៣ ៨៨៣ ៤២៧ (ថ្ងៃច័ន្ទ-ថ្ងៃសុក្រ (លើកលែងថ្ងៃឈប់សម្រាកសាធារណៈ) ចាប់ពី ០៨:០០-១២:00 និង ១៤:០០-១៧:00)

**បណ្តាញទំនាក់ទំនងសង្គម៖** https://www.facebook.com/gda.maff.gov.kh/

**គេហទំព័រ៖** http://gda.maff.gov.kh/

**គេហទំព័រ៖** https://www.ippc.int/en/countries/cambodia/

Kingdom of Cambodia
Nation Religion King

General Directorate of Agriculture

Department of Plant Protection
Sanitary and Phytosanitary

# FORMALITY OF CERTIFICATE PROVISION FOR EXPORT, RE-EXPORT, IMPORT, AND TRANSIT OF GOODS SUBJECT TO PHYTOSANITARY INSPECTION

2019

## 1. Introduction

Phytosanitary inspection aims to prevent transmission of quarantine pests and high risk pests from one area to another in the Kingdom of Cambodia, from entering-exiting, or from transiting pass by the Kingdom of Cambodia by all means in order to protect agricultural production and biodiversity.

Owners of goods which are the subjects to phytosanitary inspection brought into or transported into-out of or passed by the Kingdom of Cambodia shall request inspection and shall comply with all phytosanitary measures.

The Department of Plant Protection Sanitary and Phytosanitary of the General Directorate of Agriculture under the Ministry of Agriculture, Forestry and Fisheries has duties to directly implement phytosanitary inspection.

- Provision of Phytosanitary Certificate for Export shall be implemented in accordance with conditions stated in regulations, commercial contracts, agreements, conventions, and other documents concerning phytosanitary requirements of importing country;
- Provision of Import Certificate for goods subject to phytosanitary inspection conform to phytosanitary measures of the Kingdom of Cambodia and regional and international regulations to safeguard agricultural production, biodiversity, and international trade facilitation;
- Phytosanitary inspection of consignments transited in territory of the Kingdom of Cambodia shall be complied with Sub-Decree No. 15 dated 13 March 2003 on Phytosanitary Inspection, Law on Ratification of Protocol No. 7 on Customs Transit Systems of ASEAN Framework Agreement on the Facilitation of Goods in Transit dated 19 November 2016, and Law on Ratification of Protocol No. 8 on Sanitary and Phytosanitary Measures to implement the ASEAN Framework Agreement on the Facilitation of Goods in Transit dated 22 January 2013.

**2. Goods Subjects to Phytosanitary Inspection**

Goods which are the subjects to phytosanitary inspection include:

- Plants, parts of plant, plant products, and products recycled from plants which might be pest hosts and may spread pests;
- Packing materials, wooden cases, wood chunks, or all kinds of transports, and inventory warehouses;
- Soil or soil with root or with part of plant;
- Pest or living or dead organisms;
- Products of non-plant origins which might be pest hosts.

**3. Procedures of Phytosanitary Inspection**

**3.1. Formality of Phytosanitary Inspection for Export and Re-export**

Any natural or legal person intends to export all kinds of goods which are the subjects to phytosanitary inspection shall meet and discuss with Phytosanitary Authority of the General Directorate of Agriculture. The formality of phytosanitary inspection for export depends on type, place, origin of goods and territory or country where is importing destination (phytosanitary requirements of each country can be distinct relying on place of origin and type of goods).

Generally, the formality for export (shall be completed before export) can be:

- Types of goods which are not restricted: export of goods which are plant types and plant products from Cambodia to countries or territories of existing exportation (these governments do not require special conditions or require authorities of exporting countries to request but to implement effective legal requirements, importing requirements, and complied measures;
- Types of goods which are restricted: export of these types of goods requires the Phytosanitary Authority of Cambodia negotiates with Phytosanitary Authority of Importing Country through a request of pest risk analysis on importing of the requested goods. The negotiation may take from 1 to 5 years, and exports from Cambodian can start after the agreement, protocol, or agreed documents confirming agreement between the Phytosanitary Authorities of the importing and exporting countries. The agreement can be at regional level such as ASEAN Trade in Goods Agreement.

The formality to request phytosanitary inspection can be made in the following stages:

**A. 1st Stage: Applying**

Any natural or legal person intends to export all kinds of goods which are the subjects to phytosanitary inspection to countries or territories stating not restricted types of goods shall apply (10 days before time of export) phytosanitary inspection on consignment at the General Directorate of Agriculture (Department of Plant Protection Sanitary and Phytosanitary).

The supporting documents shall be attached with the application include: (1) Invoice, (2) Packing List, (3) Fumigation Certificate (if any and shall attach if required from importing country), (4) Import Permit (if any), (5) other phytosanitary requirements of importing country in form of agreement and protocol, etc. (if any), and (6) Phytosanitary Certificate issued by Phytosanitary Authority of country of goods of origin. * The supporting documents No. 1 to 5 are required for application of Phytosanitary

Certificate for Export and No. 6 is additionally required for application of Phytosanitary Certificate for Re-export.

**B. 2nd Stage: Inspecting and Sampling**

Any natural or legal person applied for inspection shall wait the facilitation and make appointment (when the consignments are ready) with the Phytosanitary Authority to inspect at places where consignments will be transported to ports. In case the inspection result can make the Phytosanitary Authority assumed that the inspected consignments comply or not comply with phytosanitary requirements of importing country, it is moved to the 5th stage.

**C. 3rd Stage: Diagnosing the Samples**

If no suspicions, the Phytosanitary Authority can complete inspection report and request provision of the Phytosanitary Certificate. In contrast, if any suspicions during inspection, the Phytosanitary Authority shall send the samples to Pest Diagnosis Center (take about 1-3 days additionally). If pest is found during inspection and confirmed that the consignments are not complied with phytosanitary requirements of importing country, the Phytosanitary Authority shall require the owners of the goods follow corrective actions such as fumigation which take about 5 days additionally.

In case the inspection result can make the Phytosanitary Authority assumed that the inspected consignments comply or not comply with phytosanitary requirements of importing country, it is moved to the 5th stage.

**D. 4th Stage: Corrective Actions to Comply with Phytosanitary Requirements of Importing Country**

If pest is found during inspection and/or diagnosed results of the Pest Diagnosis Center confirmed that the consignments are not complied with phytosanitary requirements of importing country, the Phytosanitary Authority shall require the owners of the goods follow corrective actions (if can be corrected) such as fumigation which take about 5 days additionally. In contrast, if cannot be corrected, the Phytosanitary Authority can refuse to make provision of the Phytosanitary Certificate (cannot export). In case the inspection result can make the Phytosanitary Authority assumed that the inspected consignments comply or not comply with phytosanitary requirements of importing country, it is moved to the 5th stage.

**E. 5th Stage: Provision or Refusal of Phytosanitary Certificate**

Reference to the inspection report of the Phytosanitary Authority (result from visual inspection, diagnosis, or inspection after the corrective actions) the consignment shall be refused or received provision of the Phytosanitary Certificate.

**3.2. Formality of Phytosanitary Inspection for Import**

Goods with potential high risks which are the subjects to phytosanitary inspection include:

- Plant seeds, fragment of plant seeds for replant, tissue culture, plant propagation, and plant genetic modification;

dated 10 May 2010 on Procedures of Phytosanitary Inspection) shall apply and follow formality to request phytosanitary inspection at phytosanitary station by attaching supporting documents as following:

(1) Phytosanitary Certificate issued by NPPO of the country of origin of goods and/or Phytosanitary Certificate for Re-export issued by Exporting Country and/or Re-exporting Country (2) Invoice, (3) Packing List, (4) Fumigation Certificate (if any), (5) Import Certificate for Plant Quarantine Material (required for goods under the List of Plant Quarantine Material with Potential High Risk Pest), (6) Import Permit issued by the Ministry of Agriculture, Forestry and Fisheries (in case goods are agricultural materials such as seeds, fertilizers, pesticides, and feeds, etc.). The cosigned goods can be allowed to be transported pass borders into the Kingdom of Cambodia in case supporting documents are submitted and the result of the inspection shows the situation of quantity, type, and phytosanitary security on the goods are complied with statements in the documents.

**D. 4th Stage: Transport, Manage, Use, Keep, or Distribute**

Every consigned goods allowed to be transported pass borders into the Kingdom of Cambodia shall be transported, managed, used, kept or distributed shall be complied with conditions required in the Import Certificate for Plant Quarantine Material and/or setting of the Phytosanitary Authority. In case of intending changes to use, keep, or distribute, the owners of goods shall apply for permit from the General Directorate of Agriculture. The owners of goods shall continuously phytosanitary security (pest introduction or provide discussion in case of pest introduction with suspicion as plant quarantine).

**3.3. Formality of Phytosanitary Inspection for Transit**

**A. 1st Stage: Transit of Goods**

- Shall transit into and out of territory of the Kingdom of Cambodia through gates indicated by the Phytosanitary Authority;
- Shall transit pass the territory of the Kingdom of Cambodia through national roads of provinces indicated by the Phytosanitary Authority;
- Shall prepare the transit by loading in closed containers which guarantee seal quality and which not be broken while being transported and shall not spread pest (if any) from the goods;
- Every means of transports and outer containers must be free from pests and regulated pest of the Kingdom of Cambodia.

**B. 2nd Stage: Phytosanitary Procedure for Transit**

- Every transit shall attach supporting documents of (1) Phytosanitary Certificate (2) Invoice, (3) Packing List, (4) Fumigation Certificate (if any);
- Every consigned goods transited pass the territory of the Kingdom of Cambodia shall be goods of place of origin;
- When every transited goods arrive gates of entry and exit, owners of goods or representatives shall request phytosanitary inspection to the Phytosanitary Authority of the General Directorate of

- Living insects, microorganism, biological agents, and fungus;
- Algae, soil or compost created from decayed plant sediments used for germination or planting or improvement of soil nutrition;
- Products, vegetable, fresh fruits and roots or buds, and mosses intended to be imported from a country of origin which has never carried out importation into Cambodia;
- Other goods which are classified in a risk level of the International Standards for Phytosanitary Measures No. 32 including No. 3 and No. 4 on the classification of goods based on the risk level caused by pest.

**A. 1st Stage: Applying**

Any natural or legal person intends to import all kinds of goods which are under the List of Plant Quarantine Material with Potential High Risk Pest (Prakas No. 346 dated 10 May 2010 on Procedures of Phytosanitary Inspection) shall beforehand apply for Import Certificate for Plant Quarantine Material at the General Directorate of Agriculture by attaching the supporting documents: (1) Pest List presented and spread in production and storage of requested goods in country of origin of the goods and countries in transits (in case transited in the 2nd country before entering the Kingdom of Cambodia) and (2) Phytosanitary Treatment documents on the requested goods. The (1) and (2) supporting documents shall documents issued by the National Plant Protection Organization of the country of origins of goods. The requested goods can be started to be imported into the Kingdom of Cambodia in case the request is provisioned the Import Certificate for Plant Quarantine Material issued by the General directorate of Agriculture and the Department of Plant Protection Sanitary and Phytosanitary directly implements phytosanitary competence and measures in accordance with phytosanitary requirements conditioned in the Import Certificate for Plant Quarantine Material.

**B. 2nd Stage: Risk Analysis**

The General Directorate of Agriculture will provide responses on results of the pest risk analysis within 15 days after the receipt of the above required supporting documents as following:

- Refuse import in case the result of pest risk assessment preliminarily shows uncontrollable risks;
- Require National Plant Protection Organization (NPPO) of country of origin of goods requests importing in case the result of pest risk assessment cannot be clearly analyzed. In such case, the above NPPO shall provide relevant documents of productions of requested goods to support the pest risk assessment; the pest risk assessment can include sending the Phytosanitary Authority of Cambodia to directly inspect production places and the cost is shouldered by the requesting party;
- Provision Import (Import Certificate for Plant Quarantine Material) in case the result of pest risk assessment shows controllable risks (with conditions).

**C. 3rd Stage: Inspecting**

Any natural or legal person intends to import all kinds of goods which are under the List of Plant Quarantine Material with Potential High Risk Pest (Prakas No. 346

Agriculture and Department of Plant Protection Sanitary and Phytosanitary directly implements and follows procedures which are results of phytosanitary inspection;

- While transiting passes the territory of the Kingdom of Cambodia, owners of the goods or representatives shall keep Cambodia Plant Quarantine Seal from gate of entry until the inspection is agreed by the Phytosanitary Authority of gate of exit. Owners of the goods or representatives shall guarantee not to open, split, or add goods or other materials into the closed containers which are transited in the territory of the Kingdom of Cambodia;
- In case of accidents while transiting passes the territory of the Kingdom of Cambodia which the containers are broken, split, or opened, the owners of goods shall report immediately to the inspectors of General Directorate of Agriculture.

**C. 3rd Stage: Guarantee of Responsibility of Owners of Goods or Representatives of Owner of Goods**

- When every transited goods arrive gates of entry and exit, owners of goods shall invite and facilitate with the Phytosanitary Authority to jointly inspect with institutions standby at gates of entry and exit;
- In case of receipt a warning or notification of refusal of import from Phytosanitary Authority of Importing Country, and/or abuses of point (A) and (B) above, the General Directorate of Agriculture will stop transit without conditions.

**Phytosanitary Authority**

**Address:** Building No. 54B-49F, Street 395-656, Sangkat Teuk Laak 3, Khan Tuol Kok, Phnom Penh

**Telephone No.:** 023 883 427 (Monday-Friday (except public holidays) from 08:00-12:00 and 14:00-17:00)

**Facebook:** https://www.facebook.com/gda.maff.gov.kh/

**Website:** http://www.gda.maff.gov.kh/

**Website:** https://www.ippc.int/en/countries/cambodia/